# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញាអន្តរជាតិ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2017, 15:53
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់** អមដោយ **ឧបសម្ព័ន្ធសម្ងាត់១**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស: សម្ងាត់/Confidential

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញាអន្តរជាតិ៖**
Nicholas KOUMJIAN

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញាជាតិ៖**
ជា លាង

**ចម្លងជូន៖**

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ ទាំងអស់**

**សហមេធាវីការពារក្ដី មាស មុត**
អាង ឧត្ដម
Michael KARNAVAS

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធានផ្ទៃក្នុង[1] វិធាន ៦៦(១)[2] និង ៥៥(១០) សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") មេត្តាបំពេញកិច្ចស៊ើបសួរនានាដូចមានរៀបរាប់ខាងក្រោម។ សហព្រះរាជអាជ្ញាសូមលើកឡើងថា អនុលោមតាមយុត្តិសាស្ត្រជាធរមាន សំណើនេះមានភាពច្បាស់លាស់ពេញលេញ និង ពន្យល់អំពីមូលហេតុដែលកិច្ចស៊ើបសួរមានភាពពាក់ព័ន្ធក្នុងការស្វែងរកការពិត*តាមការវិភាគបឋម*[3] នៅក្នុងវិសាលភាពនៃការស៊ើបអង្កេត អនុលោមទៅតាមការកំហិត និងព្រំដែនដែលត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង០០៣[4]។

## II. ប្រវត្តិនីតិវិធី

1 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី ៩) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

2 អនុលោមតាមវិធាន ៦៦(១) "ភាគីទាំងអស់មានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម"។ នៅក្នុងឯកសារ **D225** សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ("សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ") កថាខណ្ឌ ៤, ៧ ស.ច.ស.អ បានពន្យាររយៈពេល ៣០ ថ្ងៃបន្ថែមទៀត។

3 ដូចបានតម្រូវដោយវិធានផ្ទៃក្នុង និង អង្គបុរេជំនុំជម្រះ។ *សូមមើល* វិធាន ៥៥(៥) ៥៥(១០) និង ៥៨(៦)។ សំណុំរឿង ០០២-**D365/2/17** សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ ("សាលដីកាស្តីពីការពិចារណាឡើងវិញ") កថាខណ្ឌ ៤៧-៤៨, ៥០។ សំណុំរឿង ០០២-**D164/4/13** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤៤។ សំណុំរឿង ០០២-**D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើស្វែងរកភ័ស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤៣។

4 សំណុំរឿង០០២-**D365/2/17** សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៩។

2. កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ បានចាប់ផ្តើមដំណើរការនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ នៅពេលសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២[5]។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[6]។

3. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានជូនដំណឹងដល់ មាស មុត ថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាថា គាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[7]។ មាស មុត ត្រូវបានចោទប្រកាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ តាមរយៈទម្រង់នៃការទទួលខុសត្រូវនានា រួមមាន ការចូលរួមទៅក្នុងសហឧក្រិដ្ឋកម្មរួម ("JCE")[8]។

4. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ស.ច.ស.អ បានជូនដំណឹងដល់ភាគីថា គាត់បានពិចារណាបិទបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣[9] និងបានផ្តល់រយៈពេល ៣០ ថ្ងៃដល់ភាគីក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម[10]។ នៅថ្ងៃដដែលនោះ ស.ច.ស.អ បានសេចក្តីដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[11]។

5. នាពេលនេះសហព្រះរាជអាជ្ញាស្នើសុំឲ្យ ស.ច.ស.អ បំពេញកិច្ចស៊ើបសួរនានាដូចពីពណ៌នាខាងក្រោម។

---

[5] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ")។ ឯកសារ **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

[6] ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម")។

[7] ឯកសារ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង")។

[8] ឯកសារ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង កថាខណ្ឌ ៦-១៥។

[9] ឯកសារ **D225** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ។

[10] ឯកសារ **D225** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ កថាខណ្ឌ ៤, ៧។

[11] ឯកសារ **D226** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧។

# សំណើសុំបំពេញកិច្ចស៊ើបសួរ

*ការចុះទៅពិនិត្យ កោះតាំង ដល់ទីកន្លែង*

6. សហព្រះរាជអាជ្ញាស្នើសុំឱ្យ ស.ច.ស ចុះទៅដល់កោះតាំង ជាមួយនឹងសាក្សី ឯក នី។ ក.ស.ច.ស មិនទាន់បានចុះទៅពិនិត្យ កោះតាំង ទេ ទោះបីជា ឯក នី និងអ្នកដទៃទៀត ផ្តល់ភ័ស្តុតាងពាក់ព័ន្ធមួយចំនួនទៅនឹងសំណុំរឿង០០៣ ក៏ដោយ។

7. ឯក នី អតីតកម្មាភិបាលម្នាក់ក្នុងកងពលធំ១៦៤ ធ្លាប់បានពិភាក្សាយ៉ាងវែងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់គាត់ជាមួយអ្នកស៊ើបអង្កេត កសចស ស្តីពីការចាប់ទូកវៀតណាមដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងការដឹកជញ្ជូនវៀតណាមនៅលើទូកទាំងនោះ ទៅកាន់កោះតាំង ជាទីកន្លែងដែលពួកគេត្រូវបានសម្លាប់ភ្លាមៗបន្ទាប់ពីនោះ[12]។ អង្គភាពរបស់គាត់បានពាក់ព័ន្ធនៅក្នុងការចាប់ទូកទាំងនោះ យ៉ាងហោចណាស់ ក៏តាមរយៈការបញ្ជាកងទ័ពជើងទឹកឱ្យស្ទាក់ទូកទាំងនោះដែរ[13]។ គាត់បានពន្យល់ថា ដំបូងទូក និងជនជាតិវៀតណាមដែលបានចាប់នឹងត្រូវបញ្ជូនទៅកំពង់សោម ប៉ុន្តែថា ក្រោយមកថ្នាក់ដឹកនាំកងពលធំ១៦៤ បានបញ្ជាឱ្យសម្លាប់អ្នកដែលបានចាប់ខ្លួនទាំងនោះនៅលើកោះនោះ និងសាកសពធ្វើជាជីក្រោយរឹកអូសយកមាសពួកគេរួចហើយ[14]។ គាត់ដឹងអំពីការវាយដំនិងការសួរចម្លើយដែលបានធ្វើឡើងចំពោះជនជាតិវៀតណាម នៅពេលពួកគេត្រូវបានចាប់ខ្លួន[15] ពីរបៀបដែលជនជាតិវៀតណាមទាំងនោះត្រូវបានសម្លាប់[16] និងថា គាត់បានឃើញសាកសពរបស់ពួកគេនៅក្រោយការសម្លាប់[17]។ គាត់ជាភ័ស្តុតាងអំពីការដឹង

---

[12] D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៥៧។ D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:២២, ឆ:២៩។ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៤១-៤៥។

[13] D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៣៤, ឆ:៣៦។

[14] D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៦៣។ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៤១, ឆ:៤៤។

[15] D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៣៩។

[16] D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៣៣។

[17] D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៣៣, ឆ:៣៤។ សូមមើលផងដែរ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី, ឆ:៤១-៤២។

ឮយ៉ាងច្បាស់និងយ៉ាងហ្មតចតរបស់គាត់ចំពោះការចាប់ខ្លួនជនជាតិវៀតណាមទាំងនោះ[18] ភូមិសាស្ត្រកោះតាំង ព្រមទាំងទីកន្លែងសម្លាប់ និងរណ្ដៅកប់សព[19]។ តាមពិត គាត់បាននិយាយថា ខ្លួនគាត់ផ្ទាល់ធ្លាប់បានចូលរួមក្នុងការជីករណ្ដៅកប់សពទាំងនោះ[20]។ គ្មានអ្វីដែលត្រូវឆ្ងល់ទេថា គាត់អាចនឹងនាំអ្នកស៊ើបអង្កេត កសចស ទៅកាន់ទីកន្លែងកប់សពនៃជនជាតិវៀតណាមទាំងនោះដែលត្រូវបានគេសម្លាប់ចោលនៅលើកោះតាំង ដូចបានបញ្ជាក់តាមរយៈផែនទីដែលបានគូសដោយដៃរបស់គាត់ជាភស្តុតាងស្រាប់[21] និងចម្លើយរបស់គាត់អំពីបញ្ហានេះ[22]។

8. ការចុះទៅមើលទីកន្លែងរបស់ ឯក នី ទៅកាន់កោះតាង ក៏នឹងបង្ហាញផងដែរនូវឱកាសមួយដើម្បី សួរដល់គាត់អំពីថាតើគាត់នៅចាំបានឬទេ អំពីការដាក់តាំងវ៉ាដាមួយនៅលើកោះនោះ ដោយហេតុ ថាមានសាក្សីខ្លះបានផ្ដល់សក្ខីកម្ម[23] ហើយប្រសិនបើដូច្នោះមែន ថាតើវាស្ថិតនៅកន្លែងណា។ បន្ថែមលើនេះ គាត់អាចផ្ដល់នូវព័ត៌មានពាក់ព័ន្ធនឹង ថាតើគេប្រើប្រាស់វ៉ាដានោះយ៉ាងដូចម្ដេចដើម្បី ចាប់ទូកទាំងនោះ និង រៀបរាប់ពីការសម្របសម្រួល និងការប្រាស្រ័យទាក់ទងគ្នា រវាងស្ថានីយ៍ វ៉ាដានោះ និងស្ថានីយ៍វ៉ាដាដទៃទៀតដែលមានទីតាំងនៅកន្លែងផ្សេង រួមទាំង ភ្នំបូកគោផង[24]។ បន្ថែមលើនេះ ឯក នី ដូចដែលបានបង្ហាញជាភស្តុតាងដោយផែនទីគូរដោយដៃ ដែលគាត់បានផលិត

---

18 D114/284 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:១៣, ឆ:១៤។ D114/282 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:៦១។

19 សូមមើល ជាឧទាហរណ៍, D114/283 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:២៣, ឆ:២៥, ឆ:៦០។ D114/282 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:៥៧។ D114/284 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:១៣-១៤។

20 D114/284 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:១៥។

21 D114/284.1 ឯកសារភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី។

22 D114/283 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ:២៤។

23 *សូមមើល ឧ.*, D59/1/1.14 បទសម្ភាសន៍របស់ DC-Cam ជាមួយ ហ៊ីង អ៊ុច, EN 00970745។ D59/1/1.11a បទសម្ភាសន៍របស់ DC-Cam ជាមួយ ហៀង រ៉េត, EN 00974105។ D2/9 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ប៊ិន, ឆ.៤១។ D114/186 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ចក់, ឆ.១០១, ១០៤។ *សូមអានផងដែរ* D54/13.1 កំណត់ហេតុអង្គប្រជុំកងពល១៦៤ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦, EN 00974010។

24 D54/13.1 កំណត់ហេតុអង្គប្រជុំកងពល១៦៤ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦, EN 00974008 (រៀបរាប់អំពីការរៀបចំវ៉ាដានៅបូកគោ, កោះកុង, និង កោះតាង)។ D1.3.34.21 ទូរលេខយោធារបស់កម្ពុជាប្រជាធិបតេយ្យ, ១៧ មិថុនា ១៩៧៧, EN 00324804 (រៀបរាប់ពីរបាយការណ៍វ៉ាដាបូកគោ)។ D114/186 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ចក់, ឆ.៧៩ (រៀបរាប់ពីការសម្របសម្រួលរវាងវ៉ាដានៅបូកគោ និង កោះតាង)។

ឡើង[25] គឺអាចបង្ហាញបានពីទីកន្លែងពាក់ព័ន្ធផ្សេងៗទៀតនៃអាគារនានាដែលបានប្រើប្រាស់ ដោយកងវរសេនាធំ ៦២ នៅលើកោះតាង ដូចជា បញ្ជាការដ្ឋាន និងផ្ទះរបស់ មាញ មេបញ្ជាការ កងវរសេនាធំ ៦២, បន្ទប់ប្រាស្រ័យទាក់ទងវិទ្យុរបស់កងវរសេនាធំ ៦២[26], កំពង់ផែដែលកប៉ាល់ វៀតណាមដែលបានចាប់នោះចូលចត និងទីកន្លែងដែលពួកវៀតណាមត្រូវបានចាប់ខ្លួន ត្រូវបានឃុំឃាំងជាបណ្ដោះអាសន្ន និងត្រូវបានសួរចម្លើយ នៅមុនការសម្លាប់ពួកទាំងនោះ[27]។

*ការស្ដាប់ចម្លើយសាក្សីបន្ថែមទៀត ពាក់ព័ន្ធនឹង កងកេង*

9. សហព្រះរាជអាជ្ញាស្នើសុំឱ្យ ស.ច.ស ធ្វើការស្ដាប់ចម្លើយ មាស អ៊ឹម ឡើងវិញ ដែលជាប្អូនប្រុសរបស់ មាស មុត ដើម្បីសាកសួរគាត់អំពីតួនាទីរបស់គាត់នៅ កងកេង ដែលជាទីកន្លែងធ្វើការដោយបង្ខំ។ ទោះបីជា ក.ស.ច.ស បានសួរ មាស អ៊ឹម បីដងហើយក៏ដោយ[28] ក៏មិនមានការសួរសំណួរគាត់អំពីតួនាទីរបស់គាត់នៅ កងកេង នោះឡើយ។ មានហេតុផលគួរឱ្យជឿជាក់ថា មាស អ៊ឹម មានតួនាទីសំខាន់មួយទាក់ទងនឹងទីតាំងការងារដោយបង្ខំនៅ កងកេង នោះ។ សំ សោម ដែលត្រូវបានចាត់តាំងឱ្យធ្វើស្រែនៅប្រលានយន្តហោះ កងកេង ក្នុងឆ្នាំ១៩៧៧ ថ្លែងថា គាត់ស្ថិតនៅក្នុងកងចល័តក្រោម "តាអ៊ឹម"។ គាត់បន្តថា៖ "តាអ៊ឹម គឺជាកម្មាភិបាលជាន់ខ្ពស់បន្ទាប់ពី មាស មុត។ អ៊ឹម ជាអ្នកមើលការងារនៅការដ្ឋាន កងកេង ហើយគាត់ជាអនុមេបញ្ជាការកងពល ១៦៤ ទទួលបន្ទុកភស្តុភារ។ តាមដែលខ្ញុំដឹង អ៊ឹម ប្រហែលជាសាច់ញាតិរបស់ មាស មុត តែខ្ញុំមិនដឹងថាគាត់ជាបងប្អូនបង្កើត ឬជាជីដូនមួយទេ"[29]។ នៅក្នុងការស្ដាប់ចម្លើយបន្ទាប់ សំ សោម បានកំណត់អត្តសញ្ញាណ តាអ៊ឹម ថាជា មាស អ៊ឹម[30] និងនិយាយថាគាត់ "ទទួលខុសត្រូវគ្រប់ការដ្ឋានទាំងអស់រួមទាំងការដ្ឋាននៅ កងកេង ផង"[31]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យសួរសំណួរ មាស

---

25 D114/284.1 ឯកសារភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី។

26 D114/283 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ.៥៣-៥៥។ D114/284 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ.១៣។ សូមអានផងដែរ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ.៣៨។

27 អំពីការសួរដេញដោល៖ D114/283 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី, ឆ.៣៩-៤១។ D114/284 កំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សី ឯក នី, ឆ.១៣។

28 D114/214 កំណត់ហេតុនៃការស្ដាប់ចម្លើយ មាស អ៊ឹម។ D114/215 កំណត់ហេតុនៃការស្ដាប់ចម្លើយ មាស អ៊ឹម។ D114/216 កំណត់ហេតុនៃការស្ដាប់ចម្លើយ មាស អ៊ឹម។

29 D54/20 កំណត់ហេតុនៃការស្ដាប់ចម្លើយ សំ សោម, ឆ.១៤។

30 D114/58 កំណត់ហេតុនៃការស្ដាប់ចម្លើយ សំ សោម, ឆ.១៤-១៦។

31 D114/58 កំណត់ហេតុនៃការស្ដាប់ចម្លើយ សំ សោម, ឆ. ១៦។

អ៊ឹម អំពីលក្ខខណ្ឌ និងទីតាំងឧក្រិដ្ឋកម្មនៅ កងកេង ដែលជាកន្លែងការដ្ឋានពលកម្មដោយបង្ខំ ការរាយការណ៍ទៅ និងទទួលបញ្ជាពី ដែល មាស មុត ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះ និងថាតើ មាស មុង ធ្លាប់បានចុះទៅពិនិត្យទីតាំងនោះ។ សហព្រះរាជអាជ្ញាស្នើថា មាស អ៊ឹម ត្រូវតទល់ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សោម ប្រសិនបើចាំបាច់។

10. សហព្រះរាជអាជ្ញា ស្នើសុំឲ្យ ស.ច.ស ស្តាប់ចម្លើយ ហ៊ីង អ៊ុច ឡើងវិញ ពាក់ព័ន្ធនឹងការដឹងឮរបស់គាត់អំពីការដ្ឋាននៅកងកេង។ នៅក្នុងបទសម្ភាសរបស់គាត់ជាមួយ DC-Cam សាក្សី ហ៊ីង អ៊ុច ដែលជាអតីតកម្មាភិបាលកងពល ១៦៤ បានថ្លែងថា គាត់ត្រូវបានចាត់តាំងឲ្យទៅអាកាសយានដ្ឋានកងកេង ក្នុងឆ្នាំ១៩៧៦ ដើម្បីធ្វើស្រែ[32]។ យ៉ាងណាក៏ដោយ គាត់មិនត្រូវបានសួរអំពីការងាររបស់គាត់នៅកងកេង នៅក្នុងការស្តាប់ចម្លើយរបស់គាត់ណាមួយជាមួយនឹង កសចស នោះទេ[33]។ ដូច្នេះ សហព្រះរាជអាជ្ញា ស្នើសុំឲ្យ ក.ស.ច.ស ស៊ើបអង្កេតទៅលើលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅ នៅកងកេង ព្រមទាំងនៅតំបន់ពាក់ព័ន្ធផ្សេងៗទៀត។

11. សហព្រះរាជអាជ្ញា ស្នើសុំឲ្យ ស.ច.ស ស្តាប់ចម្លើយ នាក់ យ៉ន ពាក់ព័ន្ធនឹងការដ្ឋាន នៅកងកេង។ ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ របស់ នាក់ យ៉ន ត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា[34] តែ យ៉ាងណាក៏ដោយ វាមិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង០០៣ នៅឡើយទេ[35]។ អ្នកស៊ើបអង្កេត របស់ កសចស យល់ឃើញថា ពាក្យបណ្តឹងរបស់ នាក់ យ៉ន "មិនពាក់ព័ន្ធ"[36] នោះទេ តែយ៉ាង ណាក៏ដោយ សហព្រះរាជអាជ្ញាមិនឯកភាព នោះទេ។ ទោះបីជាពាក្យបណ្តឹងនេះ[37] នៅមិនទាន់ បានបកប្រែទាំងស្រុងឲ្យទៅជាភាសាអង់គ្លេសក៏ដោយ ក៏សេចក្តីសង្ខេបជាភាសាអង់គ្លេសមាន អាចរក

---

32 D59/1/1.14 បទសម្ភាសន៍របស់ DC-Cam ជាមួយ ហ៊ីង អ៊ុច, EN 00970738។

33 D54/81 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច។ D54/82 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច។ D54/83 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច។

34 D120 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, កំណត់សម្គាល់ជើងទំព័រលេខ១៩។

35 សហព្រះរាជអាជ្ញាបានបញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាគ យ៉ាន និងនិងសេចក្តីសង្ខេបក្នុងការដាក់ឯកសារដាច់ពីគ្នាដែលគ្របដណ្តប់ឯកសារដែលគាត់បានស្នើដាក់បញ្ចូលក្នុងសំណុំរឿងលេខ០០៣។

36 D114/296 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត, EN 01372336។

37 សំណុំរឿង០០២-D230/2.1.650a សេចក្តីសង្ខេបនៃពាក្យបណ្តឹងរបស់ នាក់ យ៉ន។

បាន[38] បញ្ជាក់ថា គាត់បានធ្វើការជាច្រើនកន្លែង នៅក្នុងកន្លែងកងកេងនេះ រួមមាន ធ្វើស្រែ ស្ទូងស្រូវ "នៅក្បែរវាលកងកេង", ដាំដំឡូង "នៅទួលក្បែរជើងភ្នំចំណោទរាម", គាស់គល់ឈើ នៅព្រៃទឹកសាប "ក្បែរមាត់សមុទ្ររាម", និង ជីកប្រឡាយទៅ "ខាងលិចតារាងយន្តហោះ"[39]។ គាត់បានផ្តល់ព័ត៌មានបន្ថែមទៀតថា ពីព្រោះតែក្រុមការងាររបស់គាត់មិនអាចបំពេញបាននូវការងារដែលបានចាត់តាំងឲ្យធ្វើ យ៉ាងហោចណាស់នៅឯការដ្ឋានមួយ "ពួកគាត់ត្រូវបានអប់រំ និងបន្ថយរបបអាហារ..."[40]។ អាស្រ័យហេតុដូច្នេះ វាទំនងយ៉ាងខ្លាំងដែលថា នាក់ យ៉ន រូបនេះ មាននូវព័ត៌មានជាយថាហេតុពាក់ព័ន្ធនឹងការដ្ឋានពលកម្មដោយបង្ខំនៅក្នុង និងនៅជុំ កងកេង និង ជាទូទៅនៅរាម។

*ការស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹង បិទត្រាង*

12. សហព្រះរាជអាជ្ញាស្នើសុំឲ្យ ស.ច.ស ស្វែងរក និងស្តាប់ចម្លើយសាក្សី ជួន ម៉ៅ។ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ D114/179 សាក្សី ស្នួន ឈុំ ត្រូវបានសួរថាតើ គាត់ដឹងថាមានអ្នកណាម្នាក់មកពីសហករណ៍ បិតត្រាំង នៅរស់ ឬទេ[41]។ គាត់កំណត់អត្តសញ្ញាណបុគ្គលម្នាក់ឈ្មោះ ជួន ម៉ៅ *ហៅ* តាម៉ៅ ដែលគាត់និយាយថារស់នៅជិតផ្ទះរបស់គាត់នៅឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ[42]។ ឯកសារសំណុំរឿងមិនបានបង្ហាញថាមានការព្យាយាមទាក់ទងសាក្សីសក្តានុពលនេះទេ។ ប៉ុន្តែ វាហាក់ដូចជាថា ស្នួន ឈុំ ស្ម័គ្រចិត្ត និងអាចនាំអ្នកស៊ើបអង្កេតទៅទីតាំងរបស់សាក្សីសក្តានុពលនេះបាន។ លើសពីនេះទៀត ក្នុងនាមជាអ្នកធ្វើការក្នុងសហករណ៍របស់ ស្នួន ឈុំ នោះ ជួន ម៉ៅ អាចផ្តល់ភ័ស្តុតាងបញ្ជាក់សក្ខីកម្មរបស់ ស្នួន ឈុំ និង/ឬផ្តល់ភ័ស្តុតាងបន្ថែមទៀត ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅបិទត្រាង។

*ការស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹង ស-២១*

13. សហព្រះរាជអាជ្ញាស្នើសុំឲ្យ ស.ច.ស ស្តាប់ចម្លើយឆ្មាំ ស-២១ ពីរនាក់ គឺឈុន ផល និង គង់ ផៃ ដែលត្រូវបានវាយតម្លៃនៅក្នុងរបាយការណ៍នៃសកម្មភាពស៊ើបអង្កេត ឯកសារលេខ D114/296

---

[38] សំណុំរឿង០០២-D230/2.1.650c សេចក្តីសង្ខេបនៃពាក្យបណ្តឹងរបស់ នាក់ យ៉ន។

[39] សំណុំរឿង០០២-D230/2.1.650c សេចក្តីសង្ខេបនៃពាក្យបណ្តឹងរបស់ នាក់ យ៉ន, EN 00445712។

[40] សំណុំរឿង០០២-D230//2.1.650c សេចក្តីសង្ខេបនៃពាក្យបណ្តឹងរបស់ នាក់ យ៉ន, EN 00445712។

[41] ឯកសារ D114/179 កំណត់ហេតុនៃការស្តាប់ចម្លើយ ស្នួន ឈុំ ឆ.៥៣។

[42] ឯកសារ D114/179 កំណត់ហេតុនៃការស្តាប់ចម្លើយ ស្នួន ឈុំ ឆ.៥៣។

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ថា "មិនអាចផ្តល់ព័ត៌មានពាក់ព័ន្ធថ្មីៗ"[43]។ ទោះបីជាពួកគាត់បានផ្តល់នូវភ័ស្តុតាងយ៉ាងទូលំទូលាយអំពីវត្តមាន និងការសម្លាប់ជនជាតិវៀតណាម ព្រមទាំងពួកបស្ចិមនៅ ស-២១ ក៏ដោយ ក៏ពួកគាត់ទាំងពីរនាក់ត្រូវបានសួរនាំនៅមុន ឬក្នុងអំឡុងពេលនៃសវនាការជំនុំជម្រះក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច (សំណុំរឿង ០០១) ប៉ុន្តែគាត់មិនត្រូវបានសួរនាំអ្វីឡើយនៅបន្ទាប់ពីនោះមក[44] ដូច្នេះហើយវាមិនពាក់ព័ន្ធទៅនឹងបញ្ហាជាក់លាក់ណាមួយនៃសំណុំរឿង០០៣នោះទេ។ ហេតុនេះហើយពួកគាត់មិនដែលត្រូវបានសាកសួរលម្អិតអំពីកាលៈទេសៈជុំវិញការចាប់ខ្លួនជនជាតិវៀតណាម ពួកបស្ចិមទាំងនោះទេ ដែលអាចថានៅលើសមុទ្រ បន្ទាប់មកការបញ្ជូនខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការសួរចម្លើយ និង/ឬ ការសម្លាប់ពួកគេនៅ ស-២១។

14. នៅពេលផ្តល់ចម្លើយ ឈុន ផល បានបញ្ជាក់ថា យ៉ាងហោចណាស់អ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសទាំងឡាយដែលគាត់បានយាមការពារនៅ ស-២១ គឺជាអ្នកនេសាទវៀតណាម៖ "អ្នកទោសវៀតណាម ដាក់នៅបន្ទប់តូចៗម្នាក់មួយ ចូលមកប្រហែលក្នុងឆ្នាំ១៩៧៨។ ខ្ញុំធ្លាប់សួរអ្នកទោសវៀតណាមដែលចេះនិយាយខ្មែរខ្លះថា គាត់មកពីតៃនិញ ហើយគាត់ជាអ្នកនេសាទត្រី គាត់មិនមែនជាទាហានទេ គាត់កំពុងនេសាទនៅសមុទ្រ នៅព្រំដែន។ [...] ខ្ញុំធ្លាប់ឃើញអ្នកទោសជនជាតិខាងបស្ចិមប្រទេសត្រូវបាននាំចូល"[45]។ គង់ ផៃ បាននិយាយអំពីវត្តមានរបស់អ្នកទោសប្រុសស្រីវៀតណាមនៅ ស-២១[46] ហើយគាត់បានឃើញពួកបស្ចិមប្រទេសចំនួនបីនាក់ ("ជនជាតិអាមេរិក") ដោយផ្ទាល់ភ្នែក ដែលម្នាក់ក្នុងចំណោមអ្នកទាំងបីនោះ ត្រូវបានគាត់លើកយកមក

---

43 D114/294 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត,, EN 01372334-35។

44 D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយ ឈុន ផល ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨។ D98/3.1.29 ប្រតិចារឹកអង្គជំនុំជម្រះសាលាដំបូង (ឈុន ផល), ១០ សីហា ២០០៩ (សវនាការជំនុំជម្រះ សំណុំរឿង០០១)។ D98/3.1.140 DC-Cam សម្ភាសន៍ជាមួយ គង់ ផៃ អតីតយុទ្ធជនមន្ទីរស២១-, ២៥ កុម្ភៈ ២០០០។ D64.1.10 US POW/MIA កំណត់ហេតុរបស់ គង់ ផៃ (របាយការណ៍ Stony Beach), ១៤ វិច្ឆិកា ២០០៤។ D1.3.32.24 & D114/37.1.7 កសព កំណត់ហេតុរបស់ គង់ ផៃ, ៩-២០ ធ្នូ ២០០៦។ D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយ គង់ ផៃ, ២៧ ធ្នូ ២០០៧។

45 D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយ ឈុន ផល, EN 00163814។ សូមមើលផងដែរ D98/3.1.29 ប្រតិចារឹកអង្គជំនុំជម្រះសាលាដំបូង (ឈុន ផល), ១០ សីហា ២០០៩ (សវនាការជំនុំជម្រះ សំណុំរឿង០០១), EN 00361868-69។

46 D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយ គង់ ផៃ, EN 00163634។

ពិពណ៌នាយ៉ាងលម្អិត[47] ប៉ុន្តែមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទីកន្លែងដែលពួកគេត្រូវបានចាប់ខ្លួន និងបញ្ជូនមកពីកន្លែងណាទេ។

15. សហព្រះរាជអាជ្ញាស្នើសុំឲ្យសួរ ឈុន ផល និង គង់ ផៃ ឲ្យបានពិស្តារអំពីជនជាតិវៀតណាម និងពួកបស្ចិមប្រទេសនៅ ស-២១ ជាពិសេស៖

- ចំនួនជនជាតិវៀតណាម និងពួកបស្ចិមប្រទេស រួមមាន ថៃ បរទេស ដែលពួកគាត់បានឃើញដោយផ្ទាល់ភ្នែកនៅ ស-២១ ព្រមទាំងចំនួនសរុបដែលពួកគាត់ដឹង។
- ទីកន្លែង និងកាលៈទេសនានានៃការចាប់ខ្លួនជនជាតិវៀតណាម និងអ្នកបស្ចិមប្រទេសទាំងនោះ និងជាពិសេសថាតើ ពួកគេខ្លះ ឬទាំងអស់ត្រូវបានចាប់ខ្លួននៅលើសមុទ្រ ឬនៅលើកោះ។
- ថាតើ ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួននោះ គឺជាអ្នកនេសាទ ជនភៀសខ្លួន អ្នកដែលគេគិតថាជាគិញ ឬទាហាន។
- អង្គភាពដែលចាប់ពួកគេ និងការដឹកជញ្ជូនពួកគេទៅកាន់ ស-២១។
- ថិរវេលានៃការឃុំឃាំងអ្នកទោសនៅ ស-២១។
- អគារឃុំខ្លួនពួកគេ រួមជាមួយនឹងលក្ខខណ្ឌពិស្តារនៃការឃុំខ្លួនពួកគេ។
- ការសួរចម្លើយ និងការធ្វើទារុណកម្មអ្នកទោសដែលអាចមាន។ និង
- ជោគវាសនាចុងក្រោយរបស់អ្នកទោស។

ពាក់ព័ន្ធនឹងអ្នកទោសបស្ចិមប្រទេសដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ ដែលមានចំនួនតិចតួចនៅ ស-២១ នោះ សហព្រះរាជអាជ្ញាស្នើសុំឲ្យ ស.ច.ស បង្ហាញរូបថតពួកគេដល់ ឈុន ផល និង គង់ ផៃ ប្រសិនបើមាន សម្រាប់គោលបំណងក្នុងការកំណត់អត្តសញ្ញាណ[48]។

[47] D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយ គង់ ផៃ, EN 00163633-34: "បន្ទាប់មកខ្ញុំយកបាយទៅឲ្យអ្នកទោសម្នាក់ក្នុងចំណោមបីនាក់នោះ ឃើញ ឌុច កំពុងសួរចម្លើយម្នាក់នោះ ប្រុស សក់ក្រហម រួញ វែងដាបស្មា សម្បុរស មានរោមទ្រូង ស្លៀកខោខ្លី មុនឌុចសួរម្នាក់នេះពាក់អាវប៉ាវ៉ាយឺតដៃខ្លី"។

16. ជាចុងក្រោយ សហព្រះរាជអាជ្ញាស្នើសុំឱ្យសាកសួរ ឈុន ផល និង គង់ ផៃ អំពីវត្តមាននៅ ស-២១ របស់កម្មាភិបាល និងយុទ្ធជនកងពល ១៦៤ និង កងពល ១១៧ រួមទាំងព័ត៌មានលម្អិតអំពីឈ្មោះ ឋានៈ ការប្រព្រឹត្ត និងជោគវាសនារបស់ពួកគេនៅ ស-២១ និងព័ត៌មានណាមួយដែលពួកគាត់អាចដឹង ពាក់ព័ន្ធទៅនឹង មាស មុត ឬមេដឹកនាំកងពល ១៦៤ ដទៃទៀត។

*ការស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹងទឹកសាប*

17. សហព្រះរាជអាជ្ញាស្នើសុំឱ្យ ស.ច.ស កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីបន្ថែមទៀតពាក់ព័ន្ធនឹងគុកមួយនៅអូរកំបុត។ នៅក្នុងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឯកសារ D114/275 ("របាយការណ៍") ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៦ សាក្សី សន ជួន ដែលជាអតីតយុទ្ធជនកងពលលេខ១៦៤ មកពីភូមិភាគបូព៌ា បានថ្លែងថា រូបគាត់ត្រូវបានឃុំខ្លួននៅក្នុងគុកតូចមួយរបស់កម្ពុជាប្រជាធិបតេយ្យ នៅ អូរកំបុត ខាងកើតជិតទឹកសាប និងថាគុកនោះស្ថិតក្រោម

---

[48] ជាពិសេស សំណុំរឿង ០០២-ឯកសារ E3/8063.8 (រូបថត David Lloyd Scott, ជនជាតិអូស្ត្រាលី); សំណុំរឿង ០០២-ឯកសារ E3/8063.21 (រូបថតជនបរទេសគ្មានអតសញ្ញាណ); សំណុំរឿង ០០២-ឯកសារ E3/8168 (រូបថត Ronald Keith Dean), សំណុំរឿង ០០២-ឯកសារ E394.1 រូបថត ស-២១ ថ្មី, P 01223834 (រូបថត ស-២១ ស្ទួន របស់ Christopher Delance) ត្រូវអានរួមគ្នាជាមួយនឹង សំណុំរឿង ០០២-ឯកសារ E3/9214 បញ្ជីឈ្មោះអ្នកទោស និងរូបថតរបស់ DC-Cam, EN 01224637, KH 00993365, FR 01224697។ ជនបរទេសផ្សេងទៀត ត្រូវបានកំណត់អត្តសញ្ញានៅ ស-២១ នោះគឺ James William (Jim) Clark (USA) និង Lance McNamara, ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ (សូមមើ D114/230.1.1 បញ្ជីឈ្មោះ ស-២១ របស់ កសចស លេខរៀងទី 13021 និង 13022); Michael Scott Deeds (USA, សូមមើលចម្លើយសារភាព ស-២១ របស់គាត់ D11/4.2.4) ត្រូវបានចាប់ខ្លួនជាមួយនឹង Chris Delance នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ (សូមមើល D114/230.1.1 បញ្ជីឈ្មោះ ស-២១ របស់ កសចស លេខ 12719 & 12720); John Dawson Dewhirst (អង់គ្លេស, សូមមើចម្លើយសារភាព ស-២១ របស់គាត់ D11/2.3) & Kerry Hamill (ណូវែលសេឡង់, សូមមើចម្លើយសារភាព ស-២១ របស់គាត់ សំណុំរឿង ០០២-ឯកសារ E3/7344 ចុះកាលបរិច្ឆេទ ១៣ តុលា ១៩៧៨; ដើមបណ្តឹងរដ្ឋប្បវេណី Rob Hamill បានបង្ហាញរូបថតរបស់បងប្រុសរបស់គាត់ Kerry Hamill ក្នុងអំឡុងពេលសវនាការសំណុំរឿង០០១ សូមមើលប្រតិចារឹក សំណុំរឿង ០០១-ឯកសារ E1/63.1 ត្រង់ [14:26], និងត្រង់ [15:03]), ត្រូវបានចាប់ខ្លួនរួមជាមួយគ្នា។ សម្រាប់ប្រភពផ្សេងទៀតអំពីវត្តមានរបស់ជនបរទេសទាំងប្រាំបីនាក់នេះនៅ ស-២១ សូមមើផងដែរ សំណុំរឿង ០០២-ឯកសារ E3/3973 បញ្ជីឈ្មោះជនបរទេសនៅ ស-២១, EN 00837565, FR 00875951, KH00006635; សំណុំរឿង ០០២-ឯកសារ E3/1553 S-21 បញ្ជីឈ្មោះអ្នកទោស ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨, EN 01236388-89, KH 00088751-52, FR 01187845; សំណុំរឿង ០០២-ឯកសារ E3/2210 S-21 បញ្ជីឈ្មោះអ្នកទោសដែលបានចូលថ្ងៃទី ២១-២៨ មេសា ១៩៧៨, EN 00181722, KH 00087035, មិនមាន FR។

ការគ្រប់គ្រងរបស់កងពល ១៦៤[49]។ គាត់បានបញ្ជាក់ថា គាត់បានឃើញនៅពេលមួយនោះមានអ្នកទោសប្រមាណជា ១០ ទៅ ២០នាក់ នៅក្នុងគុកនោះ[50]។ របាយការណ៍នោះបានកត់សម្គាល់ថា សក្ខីកម្មរបស់គាត់អាចជឿជាក់បាន ដោយសារតែសាក្សី សន ជួន អាចកំណត់ទីតាំងបានយ៉ាងច្បាស់នៃអតីតគុករបស់កម្ពុជាប្រជាធិបតេយ្យ និងការដ្ឋាននៅអូរកំបុត និងបានបញ្ជាក់បំភ្លឺអំពីទីតាំងមិនស្របគ្នា ទាក់ទិនទៅនឹងទីកន្លែងរបស់វា ដែលមាននៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយពីមុនរបស់គាត់[51]។ ដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍នោះ ទោះបីជា សន ជួន ថ្លែងថា គាត់គឺជាផ្នែកមួយនៃកងពល ១៦៤ នៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅ អូរកំបុត និងថា គុកនោះផ្ទាល់ស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ ក៏ដោយ ក៏ *"ចាំបាច់ត្រូវការព័ត៌មានបន្ថែមនៅដំណាក់កាលនេះ [ដើម្បីកំណត់] ថាតើ ទីតាំងនេះប្រតិបត្តិការស្ថិតនៅក្រោមការបញ្ជារបស់អង្គភាពរងមួយណា។ ដោយសារតែវាមានទីតាំងនៅជិតគ្នា វាក៏មិនច្បាស់ដែរថាតើ អូរកំបុត អាចត្រូវបានចាត់ទុកថាជាទីតាំងរងរបស់ ទឹកសាប ឬយ៉ាងណា [...]។ សូមផ្តល់នូវការបញ្ជាក់បន្ថែម"*[52]។

18. ដោយសារតែសក្ខីកម្មរបស់ សាន ជួន អំពីគុកអូរកំបុតរបស់កងពល ១៦៤ មានលក្ខណៈពិសេសមកទល់ពេលនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យធ្វើការស៊ើបអង្កេតបន្ថែមទៀតដើម្បីកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយអតីតបុគ្គលនៃកងពល ១៦៤ ផ្សេងៗទៀត ដែលត្រូវបានឃុំខ្លួននៅទីតាំងនោះ និងនៅរស់រានមានជីវិត បានយាមគុកនោះ ឬ មានសិទ្ធិអំណាចលើគុកនោះ ក៏ដូចជាជនស៊ីវិលណាដែលមានទីលំនៅនៅក្នុងតំបន់នោះ ដែលបានដឹងអំពីអត្ថិភាពរបស់គុកនោះ ក្នុងគោលបំណងដើម្បីកំណត់លក្ខខណ្ឌនៃការឃុំខ្លួន និងជោគវាសនារបស់អ្នកទោស រយៈពេលប្រតិបត្តិការរបស់គុកនេះ អង្គភាពដែលគ្រប់គ្រងគុកនេះនៅក្នុងកងពល ១៦៤ (វរសេនាធំ, វរសេនាតូច, អនុសេនាធំ) និងថាតើ គុកតូចនេះគឺពិតជាអង្គភាពរងរបស់មន្ទីរសន្តិសុខទឹកសាប ឬក៏មិនមែន ដោយសារតែវាមានទីតាំងនៅជិតគ្នា។

---

[49] D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ១៣ កក្កដា ២០១៦, EN 01346014, 01346020; សូមមើលផងដែរ D114/219 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន,១៥ មិថុនា ២០១៦, KH 01301510-29, មិនមាន EN, មិនមាន FR; D114/220 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន, ១៦ មិថុនា ២០១៦, KH 01301531-46, មិនមាន EN, មិនមាន FR។

[50] D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ១៣ កក្កដា ២០១៦, EN 01346020។

[51] D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ១៣ កក្កដា ២០១៦, EN 01346014, 01346019-20។

[52] D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ១៣ កក្កដា ២០១៦, EN 01346017។

*ការស្តាប់ចម្លើយកម្មាភិបាលក្នុងកងពល ១៦៤ ដែលត្រូវបានផ្តល់អត្តសញ្ញាណដោយ មាស មុត*

19. សហព្រះរាជអាជ្ញាស្នើឲ្យ ស.ច.ស ព្យាយាមស្វែងរកការបញ្ជាក់អំពីស្ថានភាពសុខភាពរបស់ ខែម ងួន ដែលបានកំណត់ដោយ មាស មុត ថាជាមេបញ្ជាការអង្គភាពដែលមានសមាជិក ៥០ នាក់ ក្នុងកងពល ៣(១៦៤) និងឈរជើងនៅកំពង់សោម[53] ហើយថាតើគាត់មានសុខភាពមាំមួនសម្រាប់ស្តាប់ចម្លើយផ្លូវការ ឬទេ។ ក.ស.ច.ស បានបញ្ជាក់ថា អ្នកស៊ើបអង្កេតម្នាក់ក្នុងចំណោមអ្នកស៊ើបអង្កេតទាំងនោះ បានទៅសួរសុខទុក ខែម ងួន នៅពេទ្យពេទ្យមិត្តភាព ខ្មែរ-សូវៀត នៅភ្នំពេញ នៅខែ វិច្ឆិកា ឆ្នាំ ២០១៥ និង ខែ មីនា ឆ្នាំ ២០១៦ និងថា ទោះបី ខែម ងួនបានបញ្ជាក់ពីការយល់ដឹងដែលមានសក្តានុពលពីអង្គហេតុពាក់ព័ន្ធនឹងសំណុំរឿង០០៣ នៅពេលធ្វើបទសម្ភាសន៍វាយតម្លៃក៏ដោយ ក៏គាត់មានជំងឺយ៉ាងធ្ងន់ មិនអាចស្តាប់ចម្លើយបានទេ នៅពេលនោះ[54]។ ទោះបីយ៉ាងណាក្តីវាហាក់ដូចជាថា គ្មានកំណត់ហេតុនៃការស៊ើបអង្កេតបន្ថែមទៅលើសុខភាពរបស់គាត់ទៀតឡើយ ចាប់ពីខែមីនា ឆ្នាំ២០១៦។

20. ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ០០៣ បញ្ជាក់យ៉ាងច្បាស់ថា ខែម ងួន ទំនងជាអាចផ្តល់ភស្តុតាងដែលពាក់ព័ន្ធ និងជឿទុកចិត្តបានយ៉ាងខ្លាំង។ បន្ថែមទៅនឹងបទសម្ភាសន៍វាយតម្លៃដែលមានលទ្ធផលវិជ្ជមានរបស់ ក.ស.ច.ស ខែម ងួន ក្នុងឆ្នាំ២០០០ ត្រូវបាននិយាយទៅកាន់អ្នកស៊ើបអង្កេតមកពីក្រសួងការពារជាតិនៃសហរដ្ឋអាមេរិក ដែលស៊ើបអង្កេតអំពីទាហានបាត់ខ្លួនក្នុងបេសកកម្ម[55]។ ខែម ងួន បង្ហាញថា គាត់មានតួនាទីដឹកនាំក្នុងកងពល ១៦៤ និងមានមូលដ្ឋាននៅកំពង់សោម ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[56] ដោយបានចូលរួមជាមួយពួកខ្មែរ

---

[53] ឯកសារ **D22.2.182** ចម្លើយទីពីររបស់ មាស មុត, កថាខណ្ឌ ៦-៧, EN 00249705-06។

[54] ឯកសារ **D222** របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៦; ឯកសារ **D114/298** របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៧; ឯកសារ **D223**។ ដីកាសម្រេចរួមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅលើសំណើស៊ើបអង្កេតទីមួយ ទីពីរ និងទីបី, ថ្ងៃទី៩ ខែមករា ឆ្នាំ ០១៧, កថាខណ្ឌ ៨ ("ដីកាសម្រេចរួម")។

[55] **D4.1.759** ការបែងចែងលើកទី៣ នៃការរៀបចំ និងប្រវត្តិបក្សកុម្មុយនីស្តខ្មែរ ខែមិថុនា ឆ្នាំ២០០០ ("កំណត់ហេតុស្តាប់ចម្លើយ ខែម ងួន (អ្នកទោសសង្គ្រាម និងអ្នកបាត់ខ្លួនក្នុងបេសកកម្ម)")។

[56] ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 003872654; ឯកសារ **D22.2.182** ចម្លើយទីពីររបស់ មាស មុត, ទំព័រ ៦-៧, EN 00249705-00249706។

ក្រហមពីដើមឆ្នាំ ១៩៧០[57]។ គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងរួមទាំង តាម៉ុក និង នួន ជា ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់ប្រហែលជាឆ្នាំ ១៩៩៩[58]។ ជាការពិតណាស់ អង្គហេតុដែលថា មាស មុត ស្គាល់គាត់ និងក្រោយមក គាត់បានសិក្សានៅប្រទេសចិន[59] បញ្ជាក់ពីភាពលេចធ្លោ និងទំនាក់ទំនងជាមួយនឹងថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ខែម ងួន ស្ថិតក្នុងដំណែងដែលអាចផ្តល់ព័ត៌មាន ទាក់ទងនឹងការវិវត្ត និងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា បុគ្គលិកយោធា ការប្រាស្រ័យទាក់ទង និងរចនាសម្ព័ន្ធអំណាច ទាំងនៅថ្នាក់ជាតិ និងជាពិសេសទាក់ទងនឹងកងពល ១៦៤[60] រួមទាំងតួនាទីរបស់ មាស មុត ក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត នៅតំបន់កំពង់សោម នៅលើសមុទ្រ និងលើកោះ រួមទាំងការចាប់ខ្លួន ឬ ការសម្លាប់ទាហានសហរដ្ឋអាមេរិកក្រោយឧបទ្ទវហេតុនៅលើ Mayaguez[61]។

*ការស្តាប់ចម្លើយរបស់សាក្សីទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ*

21. សហព្រះរាជអាជ្ញាស្នើឱ្យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយសាក្សីបន្ថែមទៀត ទាក់ទងនឹងការអនុវត្តនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់គាត់ ឯកសារ D120 ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានប្តឹងទៅសហចៅក្រមស៊ើបអង្កេតអំពីឧក្រិដ្ឋកម្មបន្ថែមទៀតស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ (រាប់បញ្ចូលទាំងអំពើ

---

57 ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន **D4.1.759** (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 00387264។

58 សូមមើល ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 00387275។ ខែម ងួន ជាអ្នកនិពន្ធ/អ្នកប្រតិចារិកនៃការស្តាប់ចម្លើយ នួន ជា, ឯកសារ **D4.1.194** សេចក្តីថ្លែងការណ៍ថ្នាក់ជាតិរបស់ ជនសង្ស័យដែលមានចំណងជើងថា " ប្រវត្តិ និងការតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ រហូតដល់ ១៩៧០" ដោយ នួន ជា, ពុំមានចុះកាលបរិច្ឆេទ។

59 ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 00387266។

60 សូមមើលឧទាហរណ៍, ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 00387265។

61 ឯកសារ **D4.1.759** ចម្លើយរបស់ ខែម ងួន (គណៈកម្មាធិការជាតិទទួលបន្ទុកឈ្លើយសឹក និងទាហានបាត់ខ្លួន), EN 00387265-66។ នេះពាក់ព័ន្ធទៅនឹងការស្លាប់នៃអ្នកទោសដែលត្រូវបានឃុំខ្លួននៅលើកោះ និងមន្ទីរសន្តិសុខវត្តអេងតាញៀន (Wat Eng Ta Nhien) ស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤។

ចាប់រំលោភសេពសន្ថវៈផងដែរ) នៅកំពង់សោម និងនៅកងពលធំលេខ ១៦៤ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងនានាដែលប្រមូលបានដោយ ក.ស.ច.ស ក្រោយពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ[62]។ ចាប់តាំងពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ មក សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចប៉ុណ្ណោះ ដែល ក.ស.ច.ស បានស្តាប់ចម្លើយ ត្រូវបានសួរសំណួរពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ ដែលអង្គការបានរៀបចំឲ្យពួកគេ ឬអ្នកផ្សេងទៀតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ កម្មាភិបាល ឬយុទ្ធជនក្នុងកងពលធំលេខ ១៦៤ មួយចំនួន មិនទាន់ត្រូវបានស្តាប់យកចម្លើយនៅឡើយទេអំពីប្រធានបទនេះ[63]។

22. ក្នុងចំណោមការស្តាប់ចម្លើយសាក្សីចំនួន ១៨៤ ឯកសារ ដែលបានធ្វើឡើង (ជាមួយសាក្សី ១៤១ នាក់ផ្សេងៗគ្នា) មានតែសាក្សីចំនួន ២៣ នាក់ប៉ុណ្ណោះ ត្រូវបានសួរសំណួរពីអាពាហ៍ពិពាហ៍ដែល មាស មុត ឬ កម្មាភិបាលក្រោមបង្គាប់របស់គាត់បានរៀបចំឡើងនៅតំបន់កំពង់សោម[64] ហើយក្នុងចំណោមសាក្សីទាំងនោះ មានសាក្សីតែ ១០ នាក់ប៉ុណ្ណោះ ត្រូវបានស្តាប់យកចម្លើយយ៉ាងលម្អិតអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ[65]។ លើសពីនេះទៀត សាក្សី ២៧ នាក់ ត្រូវបានស្តាប់ចម្លើយអំពីអាពាហ៍ពិពាហ៍ ដែលបានកើតឡើងនៅទីកន្លែងផ្សេងទៀតនៅក្នុងប្រទេស ឬអំពីអត្ថិភាពនៃគោល

---

[62] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D120 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៣, ២០-២៤។ ភស្តុតាងដែលប្រមូលបាន រួមមានឯកសារបក្សកុម្មុយនីស្តកម្ពុជាដែលមានអាយុកាលស្រដៀងគ្នា (D4.1.874, D114/36.1.59, D114/36.1.60, CF2 E3/1337) សៀវភៅមួយក្បាល (D54/74.1.20) និងចម្លើយ (ជួន ធី ៖ D4.1.1056, ម៉ា ឈឿន និង សួន វ៉ាត ៖ D59/1/1.7a, សេង អុល៖ D114/36.1.64, ប៉ែន សារិន៖ D2/7, លៀត ឡូន៖ D54/29, ដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី៖ D11/387/1 និង លុន សេង៖ D54/43)។

[63] សូមមើលបញ្ជីឈ្មោះខាងក្រោម កថាខណ្ឌ ២៨។

[64] ជេត ប៊ុណ្ណា (D114/66), ជុំ រីម (D114/38), គឹម ម៉េន (D114/113), លៀត ឡូន (D114/103), ម៉ៅ វ៉ាន់ (D114/132), មាស សាវ៉ាន (D114/32), ណាវ សុខន ហៅ កែន (D114/117), ងួន ឡាយ ហៅ អ៊ី (D114/139), ណុប ផន (D114/135), ប៉េវ រីម (D114/185), ព្រំ សម្បត្តិ (D114/109), សំ វុទ្ធី (D114/94), សែម កុល (D114/181), សេង អុល (D114/91), សេង ស៊ីន (D114/89), សាត ចក់ (D114/186), សុខ នាង (D114/83), សួន ផ (D114/121), ស្វាយ សាម៉េត (D114/78), តើ រី (D114/47), ថន ផល្លា (D114/97), អ៊ុយ ញ៉ឹក (D114/146), យឹម ស្រឿង (D114/95)។

[65] ជុំ រីម (D114/38), លៀត ឡូន (D114/103), មាស សាវ៉ាន (D114/32), ណាវ សុខន ហៅ កែន (D114/117), សំ វុទ្ធី (D114/94), សេង អុល (D114/91), សេង ស៊ីន (D114/89), សុខ នាង (D114/83), ស្វាយ សាម៉េត (D114/78), តើ រី (D114/47), យឹម ស្រឿង (D114/95)។

នយោបាយអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមានតែសាក្សី ១៤ នាក់ប៉ុណ្ណោះ ត្រូវបានស្តាប់យកចម្លើយយ៉ាងលម្អិត[66]។

23. ក្នុងចំណោមក្រុមសាក្សីដែលមានចំនួន ៥០ នាក់ ដែលត្រូវបានសួរយកចម្លើយអំពីអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សម្ភាសន៍ដែលខ្វះសំណួរចំនួន ២៣ លើប្រធានបទសំខាន់[67]។ សំណួរភាគច្រើន គឺសួរត្រឹមតែអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់សាក្សី ដែល

---

66 សាក្សីដែលត្រូវបានស្តាប់យកចម្លើយយ៉ាងលម្អិត ៖ ប៊ិត បឿន (D114/183), ជាម ញ៉ (D114/162), ចិន ផាត (D114/192), ជួន ធី (D114/123), ហែម អាង (D114/33), ហ្វូង ខន (D114/182), គឹម ផល្លី (D114/110), អ៊ឹម ហុន (D114/129), អ៊ុំ អ៊ីត (D114/120), វស់ ស៊ីយ (D114/297.1.1), សាំ គំនិត (D114/234), ស៊ីន ស៊ីសុផល (D114/75), ស៊ឹម ចំរើន (D114/224), អ៊ុក សុក (D114/53); ការស្តាប់ចម្លើយដែលមិនបានបញ្ចប់ពេញលេញ ៖ ឈូក រីន (D114/87), កុច ទុយ (D114/105), ម៉ឹង សេង (D114/209), សៅ សួ (D114/94), សំ សុង (D114/279), ហោ អោ (D114/190), កែវ សារួន (D114/171), ម៉ឹង វេត (D114/297.1.8), ណាប់ សុម៉ាលី (D114/34), ពេជ្រ ដារី (D114/148), ពិន សំអូន (D114/198), ព្រំ ម៉ុន (D114/170), សុខ រ៉េន (D114/155)។

67 ក្នុងចំណោមសាក្សីផ្សេងទៀត សំណួរតែមួយត្រូវបានសួរនៅចុងបញ្ចប់នៃការស្តាប់ចម្លើយទៅកាន់ កុច ទុយ, ម៉ឹង សេង, ប៉ែវ រឹម, សៅ សួ, សែម កុល, សាត ចក់, សំ សុង, ចន ផល្លា (ថាតើពួកគាត់បានរៀបការ ឬក៏អត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ៖ ដែលមានលេខឯកសារជាបន្តបន្ទាប់គ្នាគឺ ឯកសា D114/105 ត្រង់ ស.៤, ឯកសារ D114/209 ត្រង់ ស .៦៣, ឯកសារ D114/180 ត្រង់ ស.៦៧, ឯកសារ D114/94 ត្រង់ ស.៥០, ឯកសារ D114/181 ត្រង់ ស.៥៧, ឯកសារ D114/186 ត្រង់ ស.១៨៦, ឯកសារ D114/279 ត្រង់ ស.១២៥, ឯកសារ D114/97 ត្រង់ ស.២៥)។ សំណួរតែមួយផ្សេងទៀត ត្រូវបានសួរទៅ ណុប ផន និង សួន ផ (តើថាពួកគាត់ធ្លាប់ត្រូវបានសួរថា តើពួកគាត់ចង់រៀបការដែរឬទេ ដែលមានលេខឯកសារបន្តបន្ទាប់គ្នាគឺ ឯកសារ D114/135 ត្រង់ ស.៤៣ និង ឯកសារ D114/121 ត្រង់ ស.១៤១)។ សំណួរជាមូលដ្ឋានចំនួនបីត្រូវបានសួរទៅ ម៉ៅ វ៉ាន់ ដែលបានអះអាងថា គ្មាននរណាម្នាក់ត្រូវបានបង្ខំឱ្យរៀបការនោះទេ ដោយឆ្លើយថា ៖ "បើកងទ័ពស្រឡាញ់នារីណា រៀបការជាមួយនារីនោះទៅ មិនដែលពូគេបង្ខំឱ្យរៀបការជាមួយអ្នកនេះ ឬអ្នកនោះទេ" (ឯកសារ D114/132 ត្រង់ ឆ.១៦៨-១៧០) ។ គ្មានសំណួរដែលត្រូវបានចោទសួរអំពីការពិតដែលថា ស្ត្រីអាចត្រូវបានបង្ខំនោះទេ។ ងួន ឡាយ ហៅ អ៊ី ដែលជាអង្គរក្សរបស់ ញ៉ាន់ បានផ្តល់ព័ត៌មានលម្អិតមួយចំនួនអំពីអាពាហ៍ពិពាហ៍របស់គាត់ក្នុងឆ្នាំ ១៩៧៨ នៅទឹកសាប (ឯកសារ D114/139 ត្រង់ ឆ.៣៩, ឆ.១៣៥-១៣៩) ប៉ុន្តែគាត់មិនត្រូវបានសួរអំពីថា តើប្រពន្ធដែលគាត់បានជ្រើសរើសដោយមិនបានស្គាល់គ្នាពីមុន យល់ព្រមរៀបការជាមួយគាត់ដោយគ្មានការបង្ខិតបង្ខំដែរឬទេ ឬថាតើប្រពន្ធរបស់គាត់ថែមទាំងត្រូវគេប្រាប់ថា នាងត្រូវរៀបការមុនពិធីរៀបការនោះដែរឬទេ។ គ្មានសំណួរដែលត្រូវបានចោទសួរអំពីប្តីប្រពន្ធចំនួន៤គូផ្សេងទៀត ដែលបានរៀបការនៅថ្ងៃនោះ ប្រវត្តិរូបរៀងៗខ្លួនរបស់ពួកគេ និងមូលហេតុដែលពួកគេបានស្លាប់ក្រោយពេលដែលពួកគេបានរៀបការនោះឡើយ។ សាក្សីពាក់ព័ន្ធផ្សេងទៀតមានដូចជា៖ ជេត ប៊ុណ្ណា (D114/66), ឈូក រីន (D114/87), ហោ អោ (D114/190), កែវ សារួន (D114/171), គឹម ម៉េន (D114/113), ម៉ឹង វេត (D114/297.1.8), ណាប់ សុម៉ាលី (D114/34), ពេជ្រ ដារី (D114/148), ពិន សំអូន (D114/198), ព្រំ ម៉ុន (D114/170), សុខ រ៉េន (D114/155) និង អ៊ុយ ញឹក (D114/146)។

ត្រូវបានស្តាប់ចម្លើយក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ និងកាលៈទេសៈនៃការរៀបអាពាហ៍ពិពាហ៍ទាំងនោះ ប៉ុន្តែមិនបានសួរអំពីការដឹងឮនៃការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងអង្គភាព ឬតំបន់នោះទេ។ ការសួរសំណួរពាក់ព័ន្ធជាច្រើនមិនបានប្រដេញដូចជា៖

- ថាតើអនាគតប្តីប្រពន្ធ បានដឹងជាមុនថាពួកគេនឹងរៀបការ ឬមានឱកាសជួប ឬនិយាយជាមួយអនាគតប្តីប្រពន្ធរបស់ពួកគេមុនពេលរៀបការដែរឬទេ។

- លទ្ធភាពសម្រាប់អនាគតប្តីប្រពន្ធទាំងពីរ (និងមិនមែនតែកូនកំលោះនោះទេ) ក្នុងការបដិសេធដោយសេរីនូវការរៀបការ ដោយគ្មានការភ័យខ្លាចចំពោះផលវិបាកអវិជ្ជមានណាមួយ។

- ទោះបីមានការយល់ព្រមជាផ្លូវការដែលបានផ្តល់នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ អត្ថិភាពនៃកាលៈទេសៈបង្ខិតបង្ខំសក្តានុពល (រួមមាន ការគោរពឋានានុក្រមយោធា) ការគំរាមកំហែងដែលបានមើលឃើញ ឬការគោរពប្រណិប័តន៍ជាកាតព្វកិច្ចចំពោះការបញ្ជារបស់អង្គការ/ការគោរពនៃឋានានុក្រមកងទ័ព។

- អាយុ ប្រវត្តិរូបរបស់ប្តីប្រពន្ធទាំងអស់នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ (និងមិនមែនគ្រាន់តែជាសាក្សីបុរសម្នាក់ៗដែលត្រូវបានស្តាប់ចម្លើយ) រួមជាមួយនឹងទស្សនៈក្នុងការកំណត់ថា តើស្ត្រីមួយចំនួន ជាពិសេស ត្រូវបានបញ្ជូនមកពីកងផ្សេងៗ ក្រៅពីតំបន់កំពង់សោមដែរ ឬយ៉ាងណា។

- វត្តមានរបស់អតីតព្រះសង្ឃ ឬទាហានពិការក្នុងចំណោមអ្នកដែលកំពុងរៀបការ។

- កាលៈទេសៈជុំវិញពិធីរៀបការនោះ រួមទាំងទីតាំង អំឡុងពេល ព័ត៌មានលម្អិតអំពីអាជ្ញាធរជាគណៈអធិបតី ខ្លឹមសារនៃសុន្ទរកថាដែលបានផ្តល់ (រួមទាំងតម្រូវការក្នុងការបង្កើតកូន) ខ្លឹមសារនៃការប្តេជ្ញាចិត្តរបស់ប្តីប្រពន្ធ វត្តមាន ឬអវត្តមាននៃសមាជិកគ្រួសារ និងវិធីដែលសាមីខ្លួនកំណត់អនាគតប្តីប្រពន្ធរបស់ខ្លួននៅពេលមកដល់។

- ព័ត៌មានលម្អិតអំពីការរួមដំណេកក្រោយការរៀបអាពាហ៍ពិពាហ៍ (ឧទាហរណ៍ ផ្ទះដែលត្រូវបានរៀបចំសម្រាប់ប្តីប្រពន្ធដែលទើបរៀបការ ការឃ្លាំមើល ការគំរាមកំហែងពីអាជ្ញាធរ និង/ឬប្តី ការប្រើអំពើហិង្សា ការរំលោភសេពសន្ថវៈ)។

- ការដាក់ទោសដែលអាចកើតមានប្រឆាំងនឹងអ្នកដែលបដិសេធមិនរៀបការ ឬបដិសេធ/គេចវេះពីការរួមដំណេកក្រោយការរៀបអាពាហ៍ពិពាហ៍ (ឧ. ការអប់រំ ការបាត់បង់តួនាទី/ការចាត់តាំងសាជាថ្មី ការដកហូតសិទ្ធិផ្សេងៗទៀត ពលកម្មដោយបង្ខំធ្ងន់ធ្ងរជាងមុន ការចាប់ខ្លួន ការសម្លាប់) ។

- លទ្ធភាពនៃការលែងលះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

- មូលហេតុដែលអ្នករៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនបានលែងលះក្រោយឆ្នាំ ១៩៧៩ និង

- លទ្ធភាពដែលអ្នកយល់ព្រមរៀបអាពាហ៍ពិពាហ៍ ដើម្បីកែលម្អស្ថានភាព ឬលក្ខខណ្ឌជីវិតរបស់ពួកគេ (ឧទាហរណ៍ ជាប្រជាជនថ្មី) ឬលក្ខខណ្ឌជីវិត (ឧទាហរណ៍ ក្នុងគោលបំណងដើម្បីធ្វើការនៅក្នុងសហករណ៍ ដែលមានស្ថានភាពល្អប្រសើរជាងនៅក្នុងកងចល័ត) ឬដើម្បីជៀសវាងការតាមឃ្លាំមើលណាមួយ។

24. បញ្ហាអាពាហ៍ពិពាហ៍ មានសារៈសំខាន់ជាពិសេសទាក់ទងនឹងកងពលធំលេខ ១៦៤ ដែលមានទាហាន ៨.៥០០ នាក់ (និងមានបុរសនៅលីវជាច្រើនដែលគ្រប់អាយុរៀបការ) ប៉ុន្តែមានទាហានស្រីតែមួយកងវរសេនាតូច (កងវរសេនាតូចលេខ ១៦៧) ដែលមានទាហានប្រហែល ៤៣០ នាក់[68]។ លើសពីនេះទៀត អាពាហ៍ពិពាហ៍មិនត្រូវបានរៀបចំសម្រាប់ទាហាននៅមុនថ្ងៃទី ១៧ ខែ

---

[68] ឯកសារ D22.2.4 បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់កងពលធំលេខ ១៦៤ មកទល់ខែ កក្កដា ឆ្នាំ ១៩៧៦ [កងពលធំលេខ ១៦៤ មានសមាជិក ៨.៧១៦ នាក់ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៦ រួមទាំង ទាហានស្រ្តីចំនួន ៤៣០ នាក់ (កងវរសេនាតូចលេខ ១៦៧)]។ ឯកសារ D1.3.5.3 បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់កងពលធំលេខ ១៦៤ ដោយ មាស មុត មកទល់ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [កងពលធំលេខ ១៦៤ មានសមាជិក ៨.៦៨៥ នាក់ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ រួមទាំង ទាហានស្រ្តីចំនួន ៤៣០ នាក់ (កងវរសេនាតូចលេខ ១៦៧)]។ ឯកសារ D22.2.6 បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់កងពលធំលេខ ១៦៤ ដោយ មាស មុត មកទល់ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [កងពលធំលេខ ១៦៤ មានសមាជិក ៨.៦៨៥ នាក់ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ រួមទាំង ទាហានស្រ្តីចំនួន ៤៣០ នាក់ (កងវរសេនាតូចលេខ ១៦៧)]។ ឯកសារ D1.3.30.9 ទាក់ទងនឹងអង្គហេតុដែលថា ទាហានស្រ្តីទាំងអស់ គឺជាផ្នែកនៃកងវរសេនាតូចលេខ ១៦៧ ៖ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ត្រង់ ឆ.៦, ១៣-១៤, ១៩, ២៤ (ដែលគាត់បញ្ជាក់ថា មាន ៤ កងអនុសេនាធំ គឺកងអនុសេនាធំលេខ ៣១ លេខ ៣២ លេខ ៣៣ និងលេខ ៣៥ នៅក្នុងកងវរសេនាតូចលេខ ១៦៧)។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ត្រង់ ឆ.២-៣; ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ត្រង់ ឆ.២៦ ; ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ត្រង់ ស/ឆ.៤៦; ឯកសារ D54/17 និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ត្រង់ ឆ.១៣។

មេសា ឆ្នាំ ១៩៧៥ នោះឡើយ[69]។ ដោយសារកង្វះខាតស្ត្រីនៅក្នុងកងពលធំ វាច្បាស់ណាស់ថា អាពាហ៍ពិពាហ៍ដែលបានរៀបចំដោយកងពលធំលេខ ១៦៤ សម្រាប់ទាហានបុរសនៅកំពង់សោម ត្រូវមានការជាប់ពាក់ព័ន្ធនឹងស្ត្រីស៊ីវិល ទោះបីស្ត្រីស៊ីវិល មកពីតំបន់កំពង់សោម ឬតំបន់នៅក្រៅព្រំដែនកំពង់សោមនេះ[70]។ សំណួរពីការយល់ព្រមរបស់ស្ត្រីស៊ីវិលទាំងនោះ ដែលកំពុងធ្វើការនៅតាមបណ្តាសហករណ៍ក្នុងតំបន់កំពង់សោម ឬត្រូវបានបញ្ជូនពីតំបន់ផ្សេងៗទៀត (ជាពិសេសភូមិភាគនិរតី) គឺមានសារៈសំខាន់ខ្លាំងណាស់។ទោះបីជាមានសាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយ បានផ្តល់នូវព័ត៌មានដ៏មានតម្លៃអំពីការរៀបចំអាពាហ៍ពិពាហ៍ (ដោយបង្ខំ) បែបនេះ នៅក្នុងកងពលធំលេខ ១៦៤/តំបន់កំពង់សោម រួមទាំង មាស មុត ផ្ទាល់ ឬមេបញ្ជាការកងពលធំផ្សេងៗទៀត ដូចជា ឌឹម និង ញ៉ាន[71] សហព្រះរាជអាជ្ញាយល់ឃើញថា ការស៊ើបអង្កេតនេះ គឺមិនទាន់បានបិទបញ្ចប់ ដោយសារតែសាក្សីសំខាន់ៗនៅក្នុងកងពលធំលេខ ១៦៤ មិនត្រូវបានចោទសួរអំពី

---

69 ឯកសារ D114/36.1.64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ត្រង់ ឆ.៤៥, ឯកសារ D114/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីន ស៊ីសុផល ត្រង់ ឆ.៦៣ ("ការរៀបការចែកជាពីរដំណាក់កាល គឺបានន័យថា គេផ្អាករៀបការ ចាប់ពីឆ្នាំ ៧០ ដល់ ៧៥ នៅតំបន់រំដោះ។ ដំណាក់កាលទីពីរ ពីឆ្នាំ ៧៦ ដល់ ៧៨ ជាការរៀបការដោយបង្ខំ")។ ឯកសារ D114/36.1.64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល (ស.៤៥ ៖ "តើអង្គការអនុញ្ញាតឲ្យរៀបការនៅពេលណាមក? ស.៤៥ ៖ ប្រហែលជាក្នុងឆ្នាំ ១៩៧៦ ឬ ១៩៧៧")។

70 សូមមើលឧទាហរណ៍ ឯកសារ D114/36.1.64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ត្រង់ ឆ.២០-៣០ [ស្ត្រីវ័យក្មេងត្រូវបានជ្រើសរើសនៅក្នុងស្រុកត្រាំកក់ឲ្យទៅរៀបការជាមួយទាហាននៅកំពង់សោម]។ ឯកសារ D114/36.1.64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ត្រង់ ឆ.១៧៣-ឆ.២៤៤; ឯកសារ D114/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ហៅ កែន ; ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ត្រង់ ឆ.២៥៨ [ស្ត្រីត្រូវបានបញ្ជូនពីស្រែអំបិល និងទីកន្លែងផ្សេងទៀតឲ្យមករៀបការនៅកំពង់សោម]។

71 ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ឆ.១៦០-ឆ.១៧៨ [អាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយ ញ៉ាន់ នៅផ្ទះរបស់ មាស មុត]; ឯកសារ D59/1/1.7a ចម្លើយរបស់ ម៉ា ឈឿន (មជ្ឈមណ្ឌលឯកសារកម្ពុជា) KH 00926329 [ដែលលើកឡើងថា មាស មុត បានណែនាំគាត់ឲ្យរៀបការ] ដូចបានបញ្ជាក់ដោយឯកសារ D114/17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ា ឈឿន ឆ.២-ឆ.៥ ; ឯកសារ D114/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីមាស សារ៉ាន ឆ.១-ឆ.៥៧ [ឌឹម ជាគណៈធិបតីរៀបចំពិធីអាពាហ៍ពិពាហ៍ឲ្យប្តីប្រពន្ធ ៧១ គូ នៅរោងកុនកំពង់សោម] ឯកសារ D114/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ហៅ កែន [រៀបការជាមួយមេបញ្ជាការកងវរសេនាធំលេខ ១៤០ ឈ្មោះ ស៊ុន មុត ដោយ តា សឿន ជាគណៈធិបតី]; ឯកសារ D114/78 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆ.២២-ឆ.៣៤ [អាពាហ៍ពិពាហ៍ដែល ញ៉ាន់ ធ្វើជាគណៈធិបតី]; ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ឆ.២៤៥-ឆ.២៦៧។

បញ្ហានេះ ហើយសាក្សីស្ត្រីតិចតួចបំផុតដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ និងស្តាប់ចម្លើយ។

25. ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឲ្យ ស.ច.ស ធ្វើការកំណត់ និងស្តាប់ចម្លើយរបស់សាក្សីស្ត្រីផ្សេងទៀត ដែលបានរៀបអាពាហ៍ពិពាហ៍នៅកំពង់សោមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងស្នើឲ្យស្តាប់ឡើងវិញនូវចម្លើយរបស់សាក្សីយ៉ាងហោចណាស់ ១០ នាក់ ក្នុងចំណោមបុគ្គលដូចខាងក្រោមនេះ ជាពិសេសទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសបញ្ហានានាដែលបានលើកឡើងខាងលើ ដែលរួមមាន ឯក នី, ប៉ាក សុខ, ជុំ ជី, ព្រំ សាវ៉ាត់, អែម សុន, ប៊ាង រ៉េត, ហ៊ីង អ៊ុច, អៀម ភង់, អ៊ឹង ឆុន, មាស អ៊ឹម, មូល ឈិន, មុត ម៉ៅ, នាក់ យឿន, អ៊ូ គីម, សំ សោម, ស៊ឹម នី, សួស វណ្ណា (សុក វណ្ណា)។ លើសពីនេះទៀត ដោយសារសាក្សីបានរៀបអាពាហ៍ពិពាហ៍នៅក្នុងតំបន់កំពង់សោមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ សហព្រះរាជអាជ្ញាស្នើឲ្យមានការស្តាប់ចម្លើយប្តីរបស់ពួកគេដាច់ដោយឡែកពីគ្នា ដើម្បីរកឲ្យឃើញថា តើពួកគេពិតជាបានព្រមព្រៀងក្នុងការរៀបអាពាហ៍ពិពាហ៍ដែរឬយ៉ាងណា។

*ការស្តាប់ចម្លើយរបស់ មាស មុត*

26. សហព្រះរាជអាជ្ញាស្នើឲ្យ ស.ច.ស ទទួលយកសេចក្តីចម្លងនៃភាពយន្តឯកសារដែលមានចំណងជើងថា "បងធំទីមួយ"[72] និងដាក់ភាពយន្តនេះ រួមទាំងប្រតិចារឹករបស់ភាពយន្តឯកសារនេះ[73] ដែលមានជាសាធារណៈទៅក្នុងសំណុំរឿង ០០៣។

27. ភាពយន្តឯកសារនេះរៀបរាប់ពីការធ្វើដំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណី[74] Robert Hamill ក្នុងសំណុំរឿង០០៣ មកកាន់ប្រទេសកម្ពុជា ដើម្បីតាមដានការធ្វើដំណើររបស់បងប្រុសរបស់គាត់

72 បងធំទីមួយ, ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១២ ដែលនិពន្ធដោយ Annie Goldson និង Robert Hamill និងដឹកនាំដោយ Annie Goldson និង Peter Gilbert ព្រមទាំងផលិតដោយក្រុមហ៊ុន BNO និង Pan Pacific Productions ("បងធំទីមួយ")។

73 "ភាពយន្ត៖ បងធំទីមួយ" ដែលផលិតដោយក្រុមហ៊ុន Journeyman Pictures Ltd អាចរកមើលបានតាមរយៈគេហទំព័រ https://www.journeyman.tv/film_documents/5894/transcript/។ ប្រតិចារឹកនេះត្រូវបានភ្ជាប់ជូននៅក្នុង**ឧបសម្ព័ន្ធ ក**។ ក.ស.ព បានកត់សម្គាល់ឃើញថា ម៉ោងដែលបានដាក់សម្គាល់នៅលើប្រតិចារឹកនេះខុសរយៈពេលមួយម៉ោង។ ឧទាហរណ៍ ម៉ោងដំបូងដាក់ថា "01:00:00" ដែលគួរតែអានថា "00:00:00"។

Kerry Hamill ដែលជាជនជាតិណូវែលសេឡង់ ដែលត្រូវបានចាប់ខ្លួនដោយកម្មាភិបាលនៃកងពលធំលេខ ១៦៤ នៅលើកោះតាង ហើយត្រូវបានបញ្ជូនខ្លួនទៅកាន់មន្ទីរ ស-២១ ជាទីដែលគាត់ត្រូវបានធ្វើទារុណកម្ម និងសម្លាប់។ ភាពយន្តឯកសារនេះ រួមបញ្ចូលទាំងបទសម្ភាសន៍ជាមួយនឹង មាស មុត[75] ដោយ *ក្នុងចំណោមនោះ* គាត់អះអាងថា "ចំណាប់ខ្មាំងភាគច្រើន" នៃពួកបរទេសដែលត្រូវបានចាប់ខ្លួន ឬអ្នកនៅលើទូកផ្សេងទៀត "ត្រូវបានបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ"[76]។ ចម្លើយទាំងនេះ មានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការណ៍ដែលថា មាស មុត បានដឹងអំពីការប្រព្រឹត្តិ និងការចូលរួមពាក់ព័ន្ធរបស់គាត់ក្នុងការប្រព្រឹត្តិ ដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យទៅលើជនជាតិបរទេសដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រ និងនៅលើកោះនានាក្នុងដែនសមុទ្រ ព្រមទាំងជោគវាសនានាពេលក្រោយៗមករបស់ពួកគេ រួមទាំងការបញ្ជូនខ្លួនទៅកាន់មន្ទីរ ស-២១ ផងដែរ។ ភាពយន្តឯកសារនេះក៏ជួយបង្ហាញឲ្យឃើញពី *ចេតនាឧក្រិដ្ឋ* របស់ មាស មុត ទាក់ទងនឹងការប្រព្រឹត្តលើអ្នកដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជាខ្មាំង។ ទាក់ទងទៅនឹងគូបដិបក្ខនយោបាយ គាត់លើកឡើងថា "ក្នុងប្រទេសណាមួយក្នុងពិភពលោក វាជារឿងសកលលោកទៅហើយដែលគូបដិបក្ខនយោបាយមិនត្រូវបានលើកលែងនោះ។ ពួកគេមិនដែលទទួលបានការលើកលែងទេ [...] គ្មានប្រទេសណាមួយអនុញ្ញាតឲ្យគូបដិបក្ខរបស់ខ្លួនបន្តការប្រឆាំងរបស់ពួកគេឡើយ"[77]។ នៅក្នុងប្រធានបទអំពីអត្តិភាពសត្រូវផ្ទៃក្នុង គាត់សួរជាលក្ខណៈវោហារសាស្ត្រថា "តើជា ប៉ុល ពត មែនទេដែលបានប្រព្រឹត្តិការសម្លាប់នេះ? ឬក៏វាជាពួកឈ្លានពានដែលព្យាយាមទម្លាក់ ប៉ុល ពត ពីអំណាច ហើយរារាំងគោលនយោបាយល្អៗរបស់គាត់"[78]។

28. ភាពយន្តឯកសារនេះផ្តល់ភ័ស្តុតាងបន្ថែមទៀតអំពីស្ថានភាពនៃការឃុំឃាំង បច្ចេកទេសធ្វើទារុណកម្ម និងការសួរចម្លើយនៅមន្ទីរ ស-២១ តាមរយៈការស្តាប់ចម្លើយថ្មីៗរបស់អ្នករស់រានមានជីវិតពីមន្ទីរស-២១ គឺ វ៉ាន់ ណាត[79], ប៊ូ ម៉េង[80] និង ជុំ ម៉ី[81] ព្រមទាំង ញ៉ែម អេន[82] ដែលជាអ្នកថតរូប

---

[74] ឯកសារ **D11/2** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១១។ ឯកសារ **D11/2/1** របាយការណ៍របស់អង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី Rob Hamill ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១។

[75] បងធំទីមួយ, នៅនាទី 00:43:50-00:48:10។

[76] បងធំទីមួយ, នៅនាទី 00:44:18 និង 00:44:29។

[77] បងធំទីមួយ, នៅនាទី 00:45:43-01:46:22។

[78] បងធំទីមួយ, នៅនាទី 00:46:51។

[79] បងធំទីមួយ, នៅនាទី 01:04:45-01:05:52; 01:10:03-01:11:08; 01:13:13-01:13:59។

ប្រចាំមន្ទីរ ស-២១ និង ប្រាក់ ខាន់[83] ដែលជាអ្នកស្តាប់យកចម្លើយប្រចាំមន្ទីរ ស-២១ ដែលអះអាង និងបំពេញបន្ថែមភ័ស្តុតាងដែលទទួលបានពីសាក្សីនានានៅក្នុងសំណុំរឿង ០០៣។ វ៉ាន់ ណាត បាន អះអាងថាបានឃើញ និងស្តាប់ឮពួកបស្ចិមប្រទេសនៅមន្ទីរ ស-២១ រួមទាំង Kerry Hamill ផង ដែរ[84]។

29. សហព្រះរាជអាជ្ញាលើកឡើងថា វាមិនទំនងនោះទេថា ការស្តាប់ចម្លើយទាំងស្រុងរបស់ មាស មុត ត្រូវបានផលិតឡើងវិញនៅក្នុងភាពយន្តឯកសារនេះ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាបន្តស្នើឱ្យ ស.ច.ស ធ្វើការសាកសួរចំបាច់នានាជាមួយនឹង Robert Hamill, Peter Gilbert និង Annie Goldson ដែលជាអ្នកនិពន្ធ និងអ្នកដឹកនាំរឿង និង/ឬក្រុមហ៊ុនផលិតកម្ម BNO និងក្រុមហ៊ុន Pan Pacific Productions ដែលជាផលិតករអំពីទស្សនៈចំពោះការទទួលបានការស្តាប់ចម្លើយ ទាំងស្រុង។

30. សហព្រះរាជអាជ្ញាបន្តស្នើឱ្យ ស.ច.ស ដាក់ទៅក្នុងសំណុំរឿង ០០៣ នូវបទសម្ភាសន៍របស់ មាស មុត ជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិក[85]។ នៅក្នុងបទសម្ភាសន៍នេះ គាត់បញ្ជាក់ថា ការអនុវត្ត របស់សេនាធិកាក្នុងការកោះហៅកម្មាភិបាល រួមទាំងកម្មាភិបាលយោធានៃកងពលធំលេខ ១៦៤

---

[80] បងធំទីមួយ, នៅនាទី 01:04:04-01:04:45; 01:05:52-01:06:27; 01:11:08-01:11:36។

[81] បងធំទីមួយ, នៅនាទី 01:06:27-01:07:06។

[82] បងធំទីមួយ, នៅនាទី 00:54:45-00:58:04; 01:14:13-01:14:49។

[83] បងធំទីមួយ, នៅនាទី 01:08:25-01:10:03; 01:14:49-01:15:19។

[84] បងធំទីមួយ, នៅនាទី 01:10:03-01:11:08; 01:13:59-01:14:13។

[85] ឯកសារ **E3/9074**, ចម្លើយរបស់ មាស មុត (បទសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិក), ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ ("បទសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាមួយ មាស មុត")។ ឯកសារជាសំឡេងនៃបទសម្ភាសន៍នេះ អាចរកបាននៅក្នុងឯកសារ **E3/8999R** ដែលជាខ្សែអាត់សំឡេងនៃបទសម្ភាសន៍របស់ មាស មុត ជាមួយនឹងវិទ្យុសំឡេង សហរដ្ឋអាមេរិក។ ស្របតាមនីតិវិធីដែលចែងដោយ ក.ស.ច.ស ក្នុងឯកសារ **D209** ស្តីពីដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ ស្នើសុំព័ត៌មាន និងឯកសារបន្ថែមទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ [កោសលុប] ឯកសារក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ("ដីសម្រេចថ្ងៃទី ១៦ ខែ កញ្ញា"), កថាខណ្ឌ ១២-១៤, ១៨, សហព្រះរាជអាជ្ញាបានព្យាយាមស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងឱ្យផ្តល់ឯកសារ **E3/9074** ដែលត្រូវបាន ចាត់ចំណាត់ថ្នាក់ថាជាឯកសារ "សម្ងាត់" ក្នុងសំណុំរឿង ០០២ នោះ ទៅឱ្យមេធាវីការពារក្តីរបស់ មាស មុត។ ការ អនុញ្ញាតត្រូវបានប្រគល់ឱ្យនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧។ សូមមើលឯកសារ **E442/3/1** ដែលនិយាយអំពីអនុស្សារណៈ របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងឯកសារក្រោមចំណងជើងថា "ដីសម្រេចលើសំណើលើកទីពីររបស់សហព្រះ រាជអាជ្ញាអន្តរជាតិ សុំការអនុញ្ញាត", ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧។

ឱ្យចូលរួមក្នុងការបណ្តុះបណ្តាល គឺគ្រាន់តែធ្វើឡើងដើម្បីបញ្ជូនពួកគេទៅកាន់មន្ទីរ ស-២១ ប៉ុណ្ណោះ[86]។ គាត់លើកឡើងបន្ថែមទៀតអំពីគោលនយោបាយស្តីពីខ្មាំងដែលទទួលបានការអនុម័តរបស់បក្សកុម្មុយនីស្តកម្ពុជា[87] និងបញ្ជាក់អំពីការអនុវត្តការស៊ើបអង្កេតលើប្រវត្តិរបស់កម្មាភិបាលនានា[88]។ ហេតុដូចនេះ បទសម្ភាសន៍នេះមានការពាក់ព័ន្ធទៅនឹងការណ៍ដែលថា មាស មុត បានដឹងអំពីការបោសសម្អាតយោធានេះ ជាពិសេសរួមទាំងការបោសសម្អាតយោធានៅក្នុងកងពលធំលេខ ១៦៤ ព្រមទាំង *ចេតនាឧក្រិដ្ឋ* របស់ មាស មុត ទាក់ទងទៅនឹងគោលនយោបាយស្តីពីខ្មាំងផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។

## IV. សេចក្តីសន្និដ្ឋាន

31. សកម្មភាពដែលត្រូវបានស្នើឡើងនេះ មានភាពជាក់លាក់គ្រប់គ្រាន់ ជួយបញ្ជាក់ពីការពិត ចាំបាច់ដល់ការស៊ើបអង្កេត និងគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត។ ហេតុដូចនេះ សហព្រះរាជអាជ្ញាស្នើឱ្យសហចៅក្រមស៊ើបអង្កេតអនុវត្តនូវរាល់សំណើសុំការស៊ើបអង្កេត ដូចបានពណ៌នាខាងលើ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ២០១៧ | **សហព្រះរាជអាជ្ញាអន្តរជាតិ**<br>Nicholas KOUMJIAN | ក្រុងភ្នំពេញ | [signature and stamp] |

[86] ឯកសារ **E3/9074**, បទសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាមួយ មាស មុត, EN 00746176, 00746178។

[87] ឯកសារ **E3/9074**, បទសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាមួយ មាស មុត, EN 00746178។

[88] ឯកសារ **E3/9074**, បទសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាមួយ មាស មុត, EN 00746178។